ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation-Religion-King

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK

លេខ/N° : ២៤០/២៦ ន.ធ.ម ធ.អ.ជ.ក./ARDB

**វគ្គបណ្តុះបណ្តាល**

**ស្តីអំពី**

"**ប្រព័ន្ធវគ្គីករណ៍សាស្ត្របៃតងនៃធនាគារ** ARDB (ARDB Green Taxonomy)"

## ១. គោលបំណង

វគ្គបណ្តុះបណ្តាលនេះរៀបចំឡើងក្នុងគោលបំណងបង្កើនការយល់ដឹងរបស់បុគ្គលិកអំពីគោលការណ៍ និងការអនុវត្តប្រព័ន្ធវគ្គីករណ៍សាស្ត្របៃតងរបស់ធនាគារ ARDB ក្នុងការគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព។

## ២. ការរំពឹងទុក

បន្ទាប់ពីបញ្ចប់វគ្គសិក្សានេះ សិក្ខាកាមអាច៖

- យល់ដឹងអំពីទិដ្ឋភាពទូទៅ និងសារៈសំខាន់នៃប្រព័ន្ធវគ្គីករណ៍សាស្ត្របៃតង (Green Taxonomy)
- កំណត់ និងការចាត់ថ្នាក់បាននូវគម្រោង ឬសកម្មភាពដែលមានលក្ខណៈបៃតង ស្របតាមគោលការណ៍របស់ធនាគារ។
- ផ្សព្វផ្សាយ និងផ្តល់ព័ត៌មានត្រឹមត្រូវដល់អតិថិជន និងភាគីពាក់ព័ន្ធអំពីប្រព័ន្ធវគ្គីករណ៍សាស្ត្របៃតងរបស់ធនាគារ ARDB (ARDB Green Taxonomy)។
- រួមចំណែកក្នុងការជំរុញការអនុវត្តយុទ្ធសាស្ត្រហិរញ្ញប្បទានបៃតង និងការអភិវឌ្ឍប្រកបដោយចីរភាពរបស់ធនាគារ ARDB។

## ៣. មាតិកា

- និយមន័យនៃប្រព័ន្ធវគ្គីករណ៍សាស្ត្របៃតង (Green Taxonomy) និងពាក្យគន្លឹះសំខាន់ៗ
- ការអនុវត្តរបស់ថ្នាក់ជាតិពាក់ព័ន្ធនឹងប្រព័ន្ធវគ្គីករណ៍សាស្ត្របៃតង (Green Taxonomy) និងការអភិវឌ្ឍប្រកបដោយចីរភាព
- គំនិតផ្តួចផ្តើម និងការអនុវត្តរបស់ ARDB លើហិរញ្ញប្បទានបៃតង និងប្រព័ន្ធវគ្គីករណ៍សាស្ត្របៃតង (ARDB Green Taxonomy)
- សារៈសំខាន់នៃប្រព័ន្ធវគ្គីករណ៍សាស្ត្របៃតងរបស់ ARDB (ARDB Green Taxonomy)
- តួនាទីសំខាន់របស់បុគ្គលិកក្នុងការចូលរួមអនុវត្តប្រព័ន្ធវគ្គីករណ៍សាស្ត្របៃតងរបស់ ARDB (ARDB Green Taxonomy) ឱ្យមានប្រសិទ្ធភាពខ្ពស់

## ៤. កាលបរិច្ឆេទ និងទីកន្លែង

វគ្គបណ្តុះបណ្តាលនេះ នឹងត្រូវរៀបចំតាមកាលបរិច្ឆេទ និងទីកន្លែងដូចខាងក្រោម÷

- កាលបរិច្ឆេទ
  - ព្រឹកថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៦ វេលាម៉ោង ៩:០០ នាទី ដល់ ១១:៤៥
- ទីកន្លែង
  - សាលធំជាន់ ជាន់ទី៨ សម្រាប់បុគ្គលិកស្នាក់ការកណ្តាល
  - តាមរយៈអនឡាញ សម្រាប់បុគ្គលិកសាខា និងការិយាល័យចល័ត (លីងសម្រាប់ចូលរួម÷ https://teams.microsoft.com/meet/44533707782718?p=IHr6KAhamrdGRpHox)។

## ៥. សិក្ខាកាមគោលដៅ

វគ្គបណ្តុះបណ្តាលនេះរៀបចំឡើងសម្រាប់បុគ្គលិកទូទៅ និងចូលរួមតាមការស្ម័គ្រចិត្ត។

## ៦. គ្រូបណ្តុះបណ្តាល

លោក ថៃ ហ្សីឌី ប្រធាននាយកដ្ឋានហិរញ្ញប្បទានបៃតង។

## ៧. វិធីសាស្ត្រក្នុងការចូលរួម

លោក លោកស្រី អ្នកនាងកញ្ញា ដែលមានចំណាប់អារម្មណ៍ក្នុងការចូលរួមវគ្គបណ្តុះបណ្តាលនេះ សូមចុះឈ្មោះ តាមរយៈ Link ដូចមានភ្ជាប់ជូនមកជាមួយនេះ (https://forms.gle/FvtmYwqLW9TaNhMq7) ឱ្យបានត្រឹមថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៦។

ថ្ងៃ សុក្រ ១១រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៦

**នាយកដ្ឋានធនធានមនុស្ស**

**ប្រធាន**

**អ៊ុង ពិសិដ្ឋណាលីន**